# បទបង្ហាញស្តីពី

# “ភាតព្វកិច្ចគណនេយ្យនិងសវនកម្ម” សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

រៀបចំដោយ ÷ និយ័តករគណនេយ្យនិងសវនកម្ម

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែកក្កដា គ.ស.២០២៥

# មាតិកានុក្រម

១. ការកាន់បញ្ជីគណនេយ្យ

២. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

៣. ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ

៤. ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

៥. ពិន័យអន្តរការណ៍

៦. ករណីមិនរាងចាល ឬ ការយឺតយ៉ាវមិនបង់ប្រាក់ពិន័យអន្តរការណ៍

៧. បណ្តឹងតវ៉ាចំពោះសេចក្តីសម្រេចពិន័យអន្តរកាណ៍

៨. កម្រៃសេវាសាធារណៈ

# ១. ការកាន់បញ្ជីគណនេយ្យ

១.១. បញ្ជីគណនេយ្យ មានជាអាទិ៍÷

- ➢ បញ្ជី/ សៀវភៅទិញ
- ➢ បញ្ជី/ សៀវភៅលក់
- ➢ បញ្ជី/ សៀវភៅទទួលប្រាក់
- ➢ បញ្ជី/ សៀវភៅបង់ប្រាក់
- ➢ បញ្ជី/ សៀវភៅចាំបាច់ផ្សេងទៀត...

# ១. ការកាន់បញ្ជីគណនេយ្យ (ត)

## ១.២. ភាសា÷

- ❖ អង្គភាពមិនស្វែងរកប្រាក់ចំណេញ អាចប្រើភាសាអង់គ្លេស ÷
  - ➢ ប្រព័ន្ធគណនេយ្យកុំព្យូទ័រ និងប្រព័ន្ធកុំព្យូទ័រ ពាក់ព័ន្ធសម្រាប់ការកត់ត្រាប្រតិបត្តិការគណនេយ្យជាភាសាអង់គ្លេស
  - ➢ ត្រូវជូនដំណឹងពីការប្រើប្រាស់ភាសាអង់គ្លេសមក **ន.គ.ស.**។

# ១. ការកាន់បញ្ជីគណនេយ្យ (ត១)

## ១.២. ភាសា (ត)៖

- ឯកសារគាំទ្រដល់កិច្ចបញ្ជិកាគណនេយ្យ៖
  - ត្រូវជាភាសាខ្មែរ ឬអាចប្រើភាសាអង់គ្លេសអមជាមួយភាសាខ្មែរបាន => សម្រាប់ ឯកសារគណនេយ្យផ្ទៃក្នុង
  - អាចជាភាសាអង់គ្លេស => សម្រាប់
    - ឯកសារគណនេយ្យដែលបង្កើតចេញដោយប្រព័ន្ធកុំព្យូទ័រដែលមិនអាចប្រើជាភាសាខ្មែរបាន
    - ឯកសាររៀបចំនិងផ្តល់ដោយ ដៃគូធុរកិច្ចបរទេស ឬដោយអង្គការដៃគូ ឬម្ចាស់ជំនួយបរទេស ឬសម្រាប់ធុរកិច្ចជាមួយដៃគូធុរកិច្ចបរទេស។
  - ចំពោះឯកសារគាំទ្រការធ្វើធុរកិច្ច ឬប្រតិបត្តិការក្រៅពីភាសាខ្មែរ និងភាសាអង់គ្លេសត្រូវបកប្រែឯកសារទាំងនោះជាភាសាខ្មែរ ឬភាសាអង់គ្លេស។

# ១. ការកាន់បញ្ជីគណនេយ្យ (ត២)

១. ៣. រូបិយបណ្ណ៖ អាចជ្រើសរើសរូបិយបណ្ណមុខងារជាប្រាក់រៀល ឬរូបិយបណ្ណបរទេស តាមគោលនយោបាយគណនេយ្យរបស់ខ្លួន។

១. ៤. ការិយបរិច្ឆេទគណនេយ្យ៖

- អង្គភាពបង្កើតថ្មី (គិតចាប់ផ្តើមពីថ្ងៃនៃការបង្កើតរហូតដល់ថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល)
- រយៈពេល ១២ ខែ គិតចាប់ពី ថ្ងៃទី១ មករា ដល់ ថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល
- *ការិយបរិច្ឆេទគណនេយ្យកំណត់ផ្សេងនេះៗ សម្រាប់សកម្មភាពដែលមានលក្ខណៈពិសេស។*

# ២. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

❖ ស្តង់ដាគណនេយ្យជាធរមាន ៖

➢ អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវប្រើប្រាស់ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ CFRS For NFPEs ឬ

➢ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ឬស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម៖ CIFRS ឬCIFRS for SMEs (ត្រូវជូនដំណឹង)។

## CIFRS For NFPEs




## CIFRS For SMEs







## CIFRS









# ២. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

- ភាសា ៖ ត្រូវតែជាភាសាខ្មែរ
- រូបិយបណ្ណ ៖ ត្រូវតែជាប្រាក់រៀល ឬ (រៀល+រូបិយបណ្ណបរទេស)

**ភាតព្វកិច្ចផ្សេងទៀត៖**

- រក្សាទុកក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ គិតពីកាលបរិច្ឆេទនៃការបង្កើតឯកសារ
- *ធ្វើជាមូលដ្ឋានសម្រាប់បំពេញកាតព្វកិច្ចសារពើពន្ធ*។

# ៣. ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ

➢ អង្គភាពមិនស្វែងរកប្រាក់ចំណេញ ស្ថិតក្នុងលក្ខណៈវិនិច្ឆ័យ ទាំង ២ ដូចខាងក្រោម÷

១. ចំណាយប្រចាំឆ្នាំសរុប ចាប់ពី ២ ប៊ីលានរៀល និង

២. ចំនួនកម្មករនិយោជិក ចាប់ពី ២០ នាក់ ឡើងទៅ។

# ៤. ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

❖ **អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក ន.គ.ស. តាមប្រព័ន្ធអនឡាញចាប់ពីការិយបរិច្ឆេទគណនេយ្យ២០២១ តទៅ÷**

➢ ជាប់លក្ខខណ្ឌក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យមានកាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មឯករាជ្យរួចមក **ន.គ.ស. មិនឱ្យហួសរយៈពេល ៦ ខែ ២០ ថ្ងៃ**គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

➢ មិនជាប់លក្ខខណ្ឌក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យមានកាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ប្រចាំឆ្នាំមក **ន.គ.ស.មិនឱ្យហួសរយៈពេល ៣ខែ ២០ថ្ងៃ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

# ៥. ពិន័យអន្តរការណ៍

| លរ. | អំពើល្មើស | អនុភាពមិនស្មើទៅប្រាក់ចំណេញ |
|---|---|---|
| ក | ការប្រើការិយបរិច្ឆេទគណនេយ្យខុសពីច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ដោយគ្មានការអនុញ្ញាត | ៨០០ ០០០ រៀល |
| ខ | ការមិនប្រើភាសាខ្មែរនៅក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ | ៨០០ ០០០ រៀល |
| គ | ការប្រើរូបិយបណ្ណនៅក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ក្រៅពីប្រាក់រៀល ដោយគ្មានការអនុញ្ញាត | ៨០០ ០០០ រៀល |

# ៥. ពិន័យអន្តរការណ៍ (ត១)

| ល.រ. | អំពើល្មើស | អនុភាពមិនស្វែងរកប្រាក់ចំណេញ |
|---|---|---|
| **ឃ** | ការមិនដាក់ ឬភាពយឺតយ៉ាវក្នុងដាក់របាយការណ៍ហិរញ្ញវត្ថុ មក **ន.គ.ស.** តាមពេលវេលាកំណត់ | ១ ២០០ ០០០ រៀល |
| **ង** | ការមិនកាន់បញ្ជីគណនេយ្យ | ៦ ៤០០ ០០០ រៀល |
| **ច** | ការមិនរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន | ៦ ៤០០ ០០០ រៀល |

# ៥. ពិន័យអន្តរការណ៍ (ត២)

| ល.រ. | អំពើល្មើស | អត្រាពិន័យសម្រាប់ចំណោញ |
|---|---|---|
| ឆ | ការខកខានមិនដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ១ ៦០០ ០០០ រៀល |
| ជ | ការមិនប្រើរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមានសម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ | ៤ ៨០០ ០០០ រៀល |
| ឈ | ការមិនរក្សាទុកឯកសារគណនេយ្យតាមច្បាប់កំណត់ | ៨០០០ ០០០ រៀល |

# ៦. ករណីមិនរាងចាល និងការយឺតយ៉ាវមិនបង់ប្រាក់ពិន័យអន្តរការណ៍

## ៦.១. ករណីមិនរាងចាល

➢ ក្នុងករណីមិនរាងចាល បុគ្គលល្មើសត្រូវទទួលរងការពិន័យអន្តរការណ៍បន្ថែមជាប្រាក់ដូចខាងក្រោម÷

- **មិនរាងចាលលើកទី១** ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍គុណនឹងពីរដងនៃប្រាក់ពិន័យអន្តរការណ៍ដែលបង់លើកដំបូង
- **មិនរាងចាលលើកទី២** ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍គុណនឹងពីរដងនៃប្រាក់ពិន័យអន្តរការណ៍ដែលបង់ក្នុងករណីមិនរាងចាលលើកទី១
- **មិនរាងចាលលើកទី៣** **ន.គ.ស.** នឹងរៀបចំលិខិតស្នើសុំទៅក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីចាត់វិធានការស្របតាមច្បាប់ជាធរមានចំពោះអង្គភាពមិនស្វែងរកប្រាក់ចំណេញ។

## ៦.២. ការយឺតយ៉ាវមិនបានបង់ប្រាក់ពិន័យអន្តរការណ៍

- ក្នុងករណីបុគ្គលល្មើសមិនបានបង់ប្រាក់ពិន័យអន្តរការណ៍៖
  - ក្នុងរយៈពេល **៣០ ថ្ងៃ** ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវដំឡើងជាពីរដង
  - លើសពី **៦០ ថ្ងៃ** ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នេះនឹងត្រូវដំឡើងជាបីដង
  - ផុតរយៈពេល **៩០ ថ្ងៃ ន.គ.ស.** នឹងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

✍ **ចំណាំ** ៖ រយៈពេល ៣០(សាមសិប) ថ្ងៃ ៦០(ហុកសិប) ថ្ងៃ និង ៩០ (កៅសិប) ថ្ងៃ ចាប់គិតពីថ្ងៃបុគ្គលល្មើសទទួលបានលិខិតជូនដំណឹងអំពីការបង់ប្រាក់ពិន័យអន្តរកាណ៍ពី **ន.គ.ស.**។

# ៧. បណ្ដឹងតវ៉ាចំពោះសេចក្ដីសម្រេចពិន័យអន្តរការណ៍




✍ **ចំណាំ ÷** បណ្ដឹងទៅតុលាការ ពុំមានអនុភាពផ្អាកការអនុវត្តសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេ។

# ៦. តម្លៃសេវាសាធារណៈ

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា | សុពលភាព |
|---|---|---|---|---|
| ១ | ការប្រើថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថលសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ និងការថែទាំ ( Maintenance ) | | | |
| | អង្គភាពមិនស្វែងរកប្រាក់ចំណេញ | ២០០ ០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |
| ២ | សេវាទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុ | | | |
| | អង្គភាពមិនស្វែងរកប្រាក់ចំណេញជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ១០០ ០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |
| | អង្គភាពមិនស្វែងរកប្រាក់ចំណេញមិនជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ៦០ ០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |

# ៦. តម្រៃសេវាសាធារណៈ (ត១)

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា | សុពលភាព |
|---|---|---|---|---|
| ៣ | សេវាស្នើសុំពន្យារពេលក្នុងការបញ្ចប់ការងាររៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ | | | |
| | ៣.១.រយៈពេលមិនលើស៣០ថ្ងៃ | ២០០ ០០០ រៀល | ៥ថ្ងៃ | ១លើក |
| | ៣.២.រយៈពេលចាប់ពី៣១ថ្ងៃ ទៅដល់ ៦០ថ្ងៃ | ១៥ ០០០ រៀល/ថ្ងៃ | ៥ថ្ងៃ | ១លើក |
| ៤ | សេវាស្នើសុំពន្យារពេលក្នុងការបញ្ចប់ការងារសវនកម្មឯករាជ្យ | | | |
| | ៤.១.រយៈពេលមិនលើស៣០ថ្ងៃ | ១០០ ០០០ រៀល | ៥ថ្ងៃ | ១លើក |
| | ៤.២.រយៈពេលចាប់ពី៣១ថ្ងៃ ទៅដល់ ៩០ថ្ងៃ | ៥ ០០០ រៀល/ថ្ងៃ | ៥ថ្ងៃ | ១លើក |
| | ៤.៣.រយៈពេលចាប់ពី៩១ថ្ងៃ ទៅដល់ ១២០ថ្ងៃ | ១០ ០០០ រៀល/ថ្ងៃ | ៥ថ្ងៃ | ១លើក |
| | ៤.៤.រយៈពេលចាប់ពី១២១ថ្ងៃ ទៅដល់ ១៥០ថ្ងៃ | ២០ ០០០ រៀល/ថ្ងៃ | ៥ថ្ងៃ | ១លើក |

# ៦. គំរូសេវាសាធារណៈ (ត២)

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា | សុពលភាព |
|---|---|---|---|---|
| ៥ | លិខិតអនុញ្ញាតបដិប្បញ្ញត្តិក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យវេងសវនកម្មឯករាជ្យ | ១ 000 000 រៀល | ៣0ថ្ងៃ | ១លើក |
| ៦ | លិខិតអនុញ្ញាតផ្លាស់ប្តូរការិយបរិច្ឆេទគណនេយ្យ | ១ 000 000 រៀល | ៣0ថ្ងៃ | ១លើក |
| ៧ | ការស្នើសុំផ្លាស់ប្តូរគណនីប្រើប្រាស់ក្នុងប្រព័ន្ធ E-Filing | ៤0 000 រៀល | ១៥ថ្ងៃ | ១លើក |
| ៨ | កែតម្រូវព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុ | ១00 000 រៀល | ១៥ថ្ងៃ | ១លើក |

# ៦. កម្រៃសេវាសាធារណៈ (ត៣)

❖ **ការពន្យារពេលក្នុងការបញ្ចប់ការងាររៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងការងារសវនកម្ម**

**ការពន្យារពេលក្នុងការបញ្ចប់ការងាររៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ**

ត្រូវផ្ដល់ជូនមិនលើសពីរយៈពេល

៦០(ហុកសិប)ថ្ងៃ

**ការពន្យារពេលក្នុងការបញ្ចប់ការងារសវនកម្មឯករាជ្យ**

ត្រូវផ្ដល់ជូនមិនលើសពីរយៈពេល

១៥០(មួយរយហាសិប)ថ្ងៃ

**ករណីផ្ដល់ការពន្យាពេលលើស៦០ ថ្ងៃ(របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ) ឬ លើសពី១៥០ ថ្ងៃ(របាយការណ៍សវនកម្ម)**

អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលស្នើសុំនោះមានមូលហេតុសមស្រប ឬមានតម្រូវការចាំបាច់ **ត្រូវស្នើសុំជាលាយលក្ខណ៍អក្សរ និងទទួលបានការសម្រេចជាមុនពី ន.គ.ស.។**

**ករណីទទួលការឯកភាពពី ន.គ.ស.**

ក្នុងករណីមានការឯកភាពតាមការស្នើសុំ កម្រៃសេវាត្រូវគណនាដោយផ្អែកតាមរយៈពេល ដែលស្នើសុំពន្យារបន្ថែមនោះ គឺ ៤០,០០០(បួនម៉ឺន)រៀលក្នុងមួយថ្ងៃ។

# ៦. កម្រៃសេវាសាធារណៈ (ត៤)

❖ របៀបគណនាកម្រៃសេវាស្នើសុំពន្យារពេលបញ្ចប់ការងាររៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងការងារសវនកម្មឯករាជ្យ

## ឧទាហរណ៍ទី១

អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលដាក់លិខិតស្នើសុំពន្យារពេលក្នុងការបញ្ចប់ការងាររៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំក្នុងរយៈពេល៦០ថ្ងៃ ត្រូវគិតរយៈពេលមូលដ្ឋានតម្លៃសេវាមិនលើសពី ៣០ថ្ងៃ បូក៣០ថ្ងៃ ដែលជាចំនួនថ្ងៃនៃការស្នើសុំពន្យារពេល ដោយគណនាដូចខាងក្រោម៖

(២០០០០០ រៀល) + (៣០ x ១៥០០០ រៀល) = ៦៥០០០០ រៀល

ដូចនេះ កម្រៃសេវាត្រូវបង់គឺ ៦៥០ ០០០ រៀល។

# ៦. កម្រៃសេវាសាធារណៈ (ត៥)

❖ **របៀបគណនាកម្រៃសេវាស្នើសុំពន្យារពេលបញ្ចប់ការងាររៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងការងារសវនកម្មឯករាជ្យ**

## <u>ឧទាហរណ៍ទី២</u>

អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលដាក់លិខិតស្នើសុំពន្យារពេលក្នុងការបញ្ចប់ការងារសវនកម្មឯករាជ្យក្នុងរយៈពេល<u>១៥០ថ្ងៃ</u> ត្រូវគិតរយៈពេលមូលដ្ឋានតម្លៃសេវាមិនលើស៣០ថ្ងៃ បូក៦០ថ្ងៃ បូក៣០ថ្ងៃ បូក៣០ថ្ងៃ ដែលជាចំនួនថ្ងៃនៃការស្នើសុំពន្យារពេល ដោយគណនាដូចខាងក្រោម៖

(១០០០០០ រៀល) + (៦០ x ៥០០០ រៀល) + (៣០ x ១០០០០ រៀល) + (៣០ x ២០០០០ រៀល) = ១៣០០០០០ រៀល

ដូចនេះ កម្រៃសេវាត្រូវបង់គឺ ១ ៣០០ ០០០ រៀល។

# សូមអរគុណ!

## បណ្ដាញទំនាក់ទំនងសង្គមផ្លូវការរបស់ ន.គ.ស.

Website

Facebook

Telegram

សូមស្កេន QR Code នេះដើម្បីទទួលបានព័ត៌មាន